

# តើអ្នកមានដែលឮដែរទេ?

**ទទួលប្រាក់មកវិញបានចាប់ព $4,824 — ឬច្រើនជាងនេះ — វាអាចនៅរងចាំអ្នក!**

ចូរធ្វើបណ្តឹងពន្ធដារដើម្បីទទួលយកប្រាក់ដែលអ្នកត្រូវបានមកវិញ

ប្រាក់ដែលអ្នកត្រូវបានមកវិញពីការកាត់ពន្ធលើប្រាក់ចំណូល និង ប្រាក់ដែលអ្នកត្រូវបានមកវិញសំរាប់កូន

- ប្រសិនបើអ្នកបានធ្វើការនៅក្នុងឆ្នាំ 2008, មានកូនរស់នៅជាមួយអ្នក ហើយរកប្រាក់ចំណូលបានតិចជាង $39000

ឬ

- មិនមានកូនរស់នៅជាមួយទេ ហើយរកប្រាក់ចំណូលបានតិចជាង $13000 នោះ

**អ្នកអាចមានសិទ្ធិហើយ!** អ្នកអាចទទួលបាននូវការជួយធ្វើពន្ធ**ដោយមិនគិតថ្លៃ** ។

ចូរទូរស័ព្ទទៅក្រសួងពន្ធដារ IRS តាមរយៈលេខ **1-800-829-1040** ដើម្បីចង់ដឹងបន្ថែមទៀត ។

សំរាប់ពតិមានបន្ថែម

________________________________________

________________________________________

________________________________________

________________________________________

________________________________________

TAX CREDITS FOR PEOPLE WHO WORK
EIC AND CHILD TAX CREDIT

# ពន្ធលើប្រាក់ចំណូលដែលត្រូវបានមកវិញ និងប្រាក់ដែលត្រូវបានមកវិញសំរាប់កូន: អ្នកអាចជំពាក់ពន្ធតិច ហើយ អាចទទួលប្រាក់មកវិញបានពីក្រសួងពន្ធដារ IRS!

- ប្រសិនបើអ្នកបានធ្វើការនៅក្នុងឆ្នាំ 2008 — ពេញម៉ោង ឬមិនពេញ 8 ម៉ោង — អ្នកអាចមានសិទ្ធិទទួលប្រាក់មកវិញបាន ។
- ទោះបីជាអ្នកមិនបានបង់ពន្ធក៏ដោយ ក៏អាចទទួលបានប្រាក់មកវិញដែរ ។

## ប្រសិនបើអ្នកមានកូនរស់នៅជាមួយអ្នកលើសពីកន្លះឆ្នាំនៃឆ្នាំ 2008:

- **សំរាប់ពន្ធលើប្រាក់ចំណូលដែលត្រូវបានមកវិញ (EIC),** កូនត្រូវមានអាយុក្រោម 19 ឆ្នាំ គឺតដល់ត្រឹមឆ្នាំ 2008 (កូនសិស្ស រៀនពេញម៉ោងអាចមានអាយុក្រោម 24 ឆ្នាំ, បើជាកូនដែលពិការអាចដាក់ឈ្មោះចូលជាមួយ ទោះជាអាយុប៉ុន្មានក៏ដោយ ។)
- **សំរាប់ប្រាក់ដែលត្រូវបានមកវិញសំរាប់កូន CTC,** កូនត្រូវមានអាយុក្រោម 17 ឆ្នាំ គឺតដល់ត្រឹមឆ្នាំ 2008 ។

## ប្រសិនបើគ្មានកូនរស់នៅជាមួយអ្នកទេ:

- អ្នកអាចដាក់យក EIC បាន ប្រសិនបើអ្នកមានអាយុចន្លោះពី 25 ឆ្នាំ ទៅ 64 ឆ្នាំ គឺតដល់ត្រឹមឆ្នាំ 2008 ។

## តើខ្ញុំអាចរកចំណូលបានប៉ុន្មាន? តើខ្ញុំអាចបានប្រាក់មកវិញច្រើនជាងគេបំផុតប៉ុន្មានដែរ?

| **សំរាប់ EIC, ប្រសិនបើអ្នកមាន:** | **រកប្រាក់ចំណូលបានតិចជាង:** | **ដាក់សុំ EIC បានរហូតដល់ទៅ:** |
|---|---|---|
| កូនមួយនាក់ | $33,995 | $2,917 |
| កូនពីរនាក់ ឬលើសពីនេះ | $38,646 | $4,824 |
| គ្មានកូន | $12,880 | $438 |
| **សំរាប់ CTC, ប្រសិនបើអ្នកមាន:** | **រកបានចាប់ពី:** | **ដាក់សុំ CTC បានរហូតដល់ទៅ:** |
| កូនមួយនាក់ ឬលើសពីនេះ | $8,500 | $1,000 សំរាប់កូនម្នាក់ៗ |

*ការកំណត់ប្រាក់ចំណូលពី EIC សំរាប់អ្នកធ្វើការដែលបានរៀបការរួចហើយគឺមានចំនួន $3,000 លើសពីនេះ*

## តើខ្ញុំត្រូវធ្វើដូចម្តេច ប្រសិនបើខ្ញុំមិនមែនជាសញ្ជាតិអាមេរិកាំងផងនោះ ? ជនអន្តោប្រវេសន្តដែលធ្វើការ ហើយមានលក្ខណៈគ្រប់គ្រាន់ទៅតាមការកំណត់ អាចមានសិទ្ធិទទួលប្រាក់មកវិញបានដែរ ។

- **សំរាប់ EIC:** អ្នកធ្វើការ ប្តី/ប្រពន្ធ និងកូនទាំងអស់ដែលដាក់ប្តឹង ចាំបាច់ត្រូវមានលេខសូស្យាល់សេគួរីទីត្រឹមត្រូវ ។
- **សំរាប់ CTC:** ត្រូវមានលេខសូស្យាល់សេគួរី ឬលេខសំគាល់សំរាប់ធ្វើពន្ធដាររបស់បុគ្គលម្នាក់ (ITIN) ជាចាំបាច់ ។

## ដាក់បណ្តឹងធ្វើពន្ធដារទៅសហព័ន្ធដើម្បីបានប្រាក់ពី EIC និង CTC មកវិញ: រកកន្លែងជួយធ្វើបណ្តឹងពន្ធដារដោយមិនគិតថ្លៃ !!!

- VITA — ជំនួយការធ្វើពន្ធអាករលើប្រាក់ចំណូលដោយស្ម័គ្រចិត្ត – ជួយធ្វើពន្ធដារឱ្យដោយមិនគិតថ្លៃ ។
- ក្រុមសហគមន៍ដែលបានទទួលការហ្វឹកហ្វឺនពី VITA ។ សំរាប់រកកន្លែងដែលនៅជិតអ្នក ចូរទូរស័ព្ទទៅលេខ 1-800-829-1040.

## ប្រសិនបើអ្នកធ្វើការ, អ្នកអាចបានប្រាក់ពន្ធនេះមកវិញ ដោយមិនបាត់បង់ជំនួយពីរដ្ឋទេ

ការដែលបានប្រាក់មកវិញពី EIC និង CTC នឹងមិនត្រូវបានគេចាត់ទុកថាជាប្រាក់ចំណូលនោះទេ នៅពេលដែលអ្នកដាក់ពាក្យសុំ ឬសុំបន្ត ជំនួយ ដូចជាជំនួយហ្វូតស្តែម, អេស អេស អាយ (SSI), មេឌីខេដ, ជំនួយលុយកាក់, ឬជំនួយបង់ថ្លៃផ្ទះ ។ កម្មវិធីផ្តល់ជំនួយ ខ្លះ អាចមានការកំណត់ទៅលើរយៈពេលដែលអ្នកទុកលុយដែលបានមកវិញពីការធ្វើពន្ធដារនៅចោលក្នុងធនាគារ ។

## អ្នកអាចមានលទ្ធភាពទទួលបានការសងប្រាក់ឱ្យមកវិញខ្លះនៅលើស្ពែករបស់អ្នក

អ្នកធ្វើការខ្លះអាចទទួលបានប្រាក់ EIC ដែលបើកឱ្យចាយមុនបាន នៅលើស្ពែករបស់គេ រួចទើបបានទទួលស្ពែកពីក្រសួង IRS នៅក្រោយពេលដែលគេដាក់ពាក្យសុំយកប្រាក់ពីការបង់ពន្ធដារមកវិញ ។ ចូរទៅរកពាក្យសុំ W-5 ពីកន្លែងធ្វើការរបស់អ្នក ឬពី ក្រសួង IRS តាមរយៈលេខ 1-800-TAX-FORM (1-800-829-3676) ឬតាមអ៊ីនធឺណែត *www.irs.gov* ។